ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧ ........សហវ........

ថ្ងៃ ច័ន្ទ ៦កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងសន្និសីទសារព័ត៌មាននាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់លោកនាយក/លោកស្រីនាយិកា ក្រុមហ៊ុនកាស៊ីណូទាំងអស់នៅព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាល និងចម្លងនៃវីរុសកូវីដ-១៩ (COVID-19), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ចេញនូវវិធានការដូចខាងក្រោម៖

១. ក្រុមហ៊ុនកាស៊ីណូទាំងអស់ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្ន ចាប់ពីម៉ោង ២៤:០០ នាទី នាថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០ នេះតទៅ រហូតដល់មានការជូនដំណឹងជាថ្មី,

២. ចំពោះកាតព្វកិច្ចចំណូលប្រចាំខែ ត្រូវបានលើកលែងចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០ តទៅ រហូតដល់ថ្ងៃអនុញ្ញាតឱ្យបើកដំណើរការអាជីវកម្មឡើងវិញ,

៣. ក្នុងករណីអនុវត្តផ្ទុយពីការណែនាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចាត់វិធានការតាមច្បាប់ជាធរមាន ។

អាស្រ័យហេតុនេះ សូមលោកនាយក/លោកស្រីនាយិកាក្រុមហ៊ុនកាស៊ីណូទាំងអស់មេត្តាជ្រាប និងអនុវត្តឱ្យបានប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន